# សិលាចារឹកប្រាសាទជើងអង K.៩៩ (ភាគ២)

នៅក្នុងអត្ថបទភាគ១[1] ប្រិយមិត្ត AMS Khmer Civilization បានជ្រាបរួចមកហើយ អំពីព័ត៌មាននិងទិដ្ឋភាពទូទៅនៃសិលាចារឹកប្រាសាទជើងអង។ នៅក្នុងភាគ២នេះ យើងនឹងបកប្រែអត្ថបទសិលាចារឹកនេះ ព្រមទាំងបង្ហាញវាក្យសព្ទបុរាណមួយចំនួនផងដែរ។

## អត្ថបទប្រែសម្រួលជាភាសាខ្មែរទំនើប

### មេទ្វារខាងត្បូង

(១-៦) សិទ្ធិ សួស្តី ឆ្នាំ៨៤៤មហាសករាជ នូវមានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញស្រីជ័យវម៌្មទេវ(ទី៤ ត្រាស់)ដល់ធូលីជើងព្រះគម្តែងអញស្រីប្របិវិន្ទ្រវម៌្ម(ឱ្យ)បន្ទូលព្រះរាជសាសន៍(នេះ) ដល់ម្រតាញស្រីទ្រីបេន្ទ្រវិក្រម(ជា)ខ្លោញឃ្លាំងថ្នាក់ទី១ គប្បីបង្គាប់ប្រាសាទព្រះគម្តែងអញស្រីត្រីភូវនៃកនាថនៅឯជើងអង ដែលជាបុណ្យរបស់ឆ្លោញប្រាណ (ឱ្យ)ផ្សំគណជាមួយ(ប្រាសាទ)ព្រះគម្តែងអញស្រីចាម្បេស្វរ។

(៦-៩) ពុំជាបីមានក្តីរង្កៀសជាមួយអ្នកបំចាំ(អ្នកថែរក្សា) ពុំជាបីមានក្តីរង្កៀសជាមួយនឹងខ្លោញវិស័យ(អភិបាលវិស័យ/ខេត្ត) ខ្លោញស្រូវ ខ្លោញស្មៀន និងតម្រួតអម្រឹតកជន ដែលថ្វាយទៅដល់ព្រះគម្តែងអញស្រីចាម្បេស្វរ។

(៩-១១) ព្រះរាជសាសន៍(ត្រាស់)ប្រើរៀបរណ្តាប់បូជាមានអង្ករសេល៦ខារិកា ប៊ីរ៨អាឍក ពស្ត្រាជលស្វេត២គូ គោ១០០ក្បាល ផ្សំជាមួយជូនថ្វាកមណ្ឌលុទឹកព្រះរាជស្រី១ទម្ងន់១ជញ្ជីង។

(១១-១២) នេះ(សុទ្ធ)សឹងជារណ្តាប់បូជា(ថ្វាយ)ទៅដល់ព្រះគម្តែងអញស្រីចាម្បេស្វរសព្វឆ្នាំ។

(១២-២៩) ខ្ញុំបម្រើ(ដែល)ឆ្លោញប្រាណថ្វាយចំពោះព្រះគម្តែងអញវិស្ណុ សម្រាប់ខែវនោចះ សីកបិត(ជា)តម្រួត សីថ្ងើម(ជា)អ្នកយាមឃ្លាំង សីសិទ្ធិពរ(ជា)មេភូមិ សីកំព្រៀបេកធ្វើស្រែកំលុងប្រាសាទ សីកញ្ចោស សីថ្កាប សីបន្ទន សីកំបត សីកំបិត សីកំបិតម្នាក់ទៀត

[1] សូមចូលមើលអត្ថបទភាគ១ តាមរយៈ https://ams.com.kh/khmercivilization/detail/9827 ។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

សីម្ចូត (ជា)ចុងភៅ សីកំរុត(ជា)ចុងភៅ សីកំរិស(អ្នក)ដេញ(ឧបករណ៍ភ្លេង)។ អំរះ៖ សីក្រៅ សីកំបស តៃភាជ តៃធម៌។ (អ្នក)ធ្វើស្រែវ្នេកទ្វាយ៖ អំរះ(គឺ)សីមានុធម៌ សីបន្ទុល តៃប្រេត តៃមយ។ (អ្នកនៅ)វ្នេកទ្វាយ៖ អំរះ(គឺ)សីជង្វេរ សីកំវ្យាំ តៃកន្រ្ទប តៃបន្ទស។ (អ្នក)ធ្វើស្រែវ្នេកទ្វាយទៀតសោត៖ អំរះ(គឺ)សិថ្កោត សីកន្សិប តៃវ្រត តៃកញ្ចុ។ (អ្នក)ធ្វើស្រែវរុយ៖ អំរះ(គឺ)សីកន្សុ សីវត្នទាស សីថ្កាប សីចន្រ្ទភា សីច្បង សីកន្អា អ្មេលំញញ តៃកន្រ្ទង។ (អ្នក)ធ្វើស្រែហោងនិងស្រែត្បូងដេក៖ អំរះ(គឺ)សីវង៉ា សីអម្រឹត តៃកន្រុក តៃមាលិកា តៃស្រង។ (អ្នក)ធ្វើស្រែវ្នេកទ្វាយ៖ អំរះ(គឺ)សីចំហេក តៃកំប្រូត តៃលង្កាយ។ (អ្នក)ធ្វើស្រែជើងទំបន់៖ អំរះ(គឺ)សីកន្អន សីសំអប តៃប្រតិក តៃអ្នាយ តៃកវ្រៅ តៃកំភាត។ (អ្នក)ធ្វើស្រែបាលយា៖ តៃកន្រត តៃថ្វើម តៃថ្កេ។ (អ្នក)ធ្វើសង្វោយ តម្រទូងចាញ សីថ្កាប សីកន្អាស សីស្រី សីអម្រឹត សីធម៌ សិកញ្ជស សីតង្កេ។ អ្នកប៉ះ(សម្ភៀកបំពាក់?) តៃកណ្ដី តៃកន្ទោត តៃកំវ្យា តៃកន្សោ តៃសំអប តៃសុភាទេវ តៃសំអបសោត តៃខ្មោ តៃខ្សាយ តៃរំនោច តៃកប្រូត តៃកំបិត តៃទំទិប តៃកន្អស តៃកន្សង។ អ្នកដេញ(ឧបករណ៍ភ្លេង) តៃកញ្ចាន តៃខ្នប។ អ្នកដេរស្ទឹក តៃកន្សង។ អ្នកទុក(សម្លៀក)វស៉ា តៃសុរភី តៃព្រះប្រសាទ តៃកន្សោ តៃប្រាណ តៃសំប្ញទ្ធិ តៃផ្កា តៃកំបិត។ គង្វាល សីតកង្កេរ។ អ្នកចាំច្បារ សីសំអប សីកន្អក សីផ្កល។ អំរះជន្ទេរ៖ តៃកណ្ឌិ សីថ្កប តៃកន្អា តៃកន្រ្សច តៃកំភាក តៃកន្ស តៃខ្មៅ សីកន្អា សីតង្កុ តៃសុជាតិ តៃវត្នស្រីយ តៃកំវះ ឱ្យកំបោរ។ ផ្សំអ្នក(បម្រើ)ខែរនោច(មាន)១១៧នាក់។

(២៩-៣០) ជំនូនព្រាហ្មណ៍៖ សីមុនីទាស។

(៣០-៣២) ព្រះរាជសាសន៍ប្រើយជមានរៀបចំឱ្យអំរះម្នាក់ៗ(មាន)៖ សណ្ដែក១ដើ និង៨លិះ ល្ងចលិះ រង្វ២មាស អង្ករសម្រាប់បូជាយជ្ញរាល់ថ្ងៃ២ថ្លោង នំចុន សណ្ដែកហូប ព្រីង វទិ វទា ផុរិ ផុរា គ្រលេង ប្រេងក្រអូប កំបោរ/កំបោរ(?) បរិមាណ ទឹកដោះគោ ធមាយ រាយវក សម្ទស្ទោរ។ នេះ(សម្រាប់)ខែរនោច។

(៣៣-៣៤) នរូណាលួច(យកនូវទ្រព្យទាំងឡាយ)និងល្មើសរាជបញ្ញា នឹងត្រូវធ្លាក់ទៅនរកដរាបណាព្រះចន្រ្ទនិងព្រះអាទិត្យនៅតែមាន។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## មេទ្វារខាងជើង

(១-២៤) សិទ្ធិ សួស្តី។ ជំនូនខ្ញោញវិស និងតាញស្តេងបញ និងតាញស្តេងបិ និងតាញស្តេងពៅវ (ថ្វាយ)ចំពោះប្រាសាទព្រះគម្តែងអញស្រីត្រីភូវនៃកនាថនៅឯជើងអង។ សីអម្រឹទុការ(ជា)អ្នកត្រួត សីកំបិង(ជា)មេភូមិ សីថ្វស(ជាអ្នក)យាមឃ្វាំង សីនរាយ(ជាអ្នក)បើក សីចំហេក(ជាអ្នក)បេះ/ក្រងផ្កា សីកន្សិប(ជា)ចុងភៅ សីបវិត្រ(ជា)ចុងភៅ សីកញ្ចួន(ជា)ចុងភៅ។ អ្នកធ្វើការះ តែតំបញ សីថ្គប សីកំវាស សីថ្ងើម សីផ្លក។ អ្នករាំ(?) តែកទ្រៅ តែថ្នាស(ជាអ្នក)រាំ តែត្លក តែកំវៃ តែធ្វប តែកនសំអប។ (អ្នក)យាមឃ្វាំង៖ តែគន្ធ តែរំនោច តែសអប តែបន្សំ តែកទ្រូច តែកន្សេស តែកន្តេង តែកំព្រៅ។ អ្នករាំកន្និ(ល្ខោនពោល) សីចាប្ប សីអង្កាំ សីកន្ទេង។ (អ្នក)ទូង(ស្គរ) សីកន្អាត។ អ្នកបម្រើផ្កាប្រាង្គ ចន្ទ្រវារ។ អ្នកទុកសម្លៀកវស៉ា៖ តែកំវេត តែកន្អញ តែធរ តែឆ្នើម តែកន្សេរា តែកន្សសោ។ អំរះ៖ សីជីវ សីកញ្ចេស សីកន្សេរា តែសំកោ តែកញ្ចុ។ អំរះ៖ សីថ្គោត សីកញ្ចុ សីអគត តែកំប្រូត តែឆ្មោង។ អំរះ៖ សីរំនោច តែកំប្រូត តែឧត្បល តែបន្ទុន។ អំរះ៖ សីកំបញ សីសំអប តែលង្គាយ តែកំបិត តែប្រាណ។ (អ្នកទាំង)នេះ(សុទ្ធ)សឹងធ្វើស្រែបាសទិងទេង៖ អំរះគឺសីកទ្រោ សីខ្ញុំ សីកញ្ចួ តែកញ្ចែយ តែកន្ធន។ (អ្នក)ធ្វើស្រែត្បូងដេក(ទិសខាងត្បូង)៖ អំរះគឺសីខ្វាង តែកំវៃ តែកំវៃម្នាក់ទៀត។ (អ្នក)ធ្វើស្រែបាសទិងទេង៖ អំរះគឺសីបន្ទុស សីបន្ទុន សីកំវៃ តែខ្មៅ។ (អ្នក)ធ្វើស្រែបាលយា៖ អំរះគឺសីខ្នេត សីកន្អក។ (អ្នក)ធ្វើស្រែសមាទិជន៖ អ្នកចាំច្បារ សីកំព្រា សីកទ្រោ សីតង្កើរ តែកញ្ចាន តែកញហ្យង។ (អ្នក)ទុកព្រះវសន៖ តែប្ញូ តែធម៌ តែកន្សេរា តែថ្នោស តែកញ្ចិរ ម្តាយតែផ្ទិត សីសំវារ សីធម៌ សីកន្សៀ/កន្ទៀ។ អំរះគឺ សីមហេន្ទ្រទាស សីកំវុត សីកំវៃ សីកំបញ សីអម្រឹត តែបន្ទុន។ (អ្នក)ធ្វើស្រែត្បូងដេក៖ សីកំព្រៅវ សីចំហេក សីថ្គេ សីកញ្ចោស សីទំលុះ សីអ្នាយ សីថ្កេ សីកនឥ សីបំនោះ តែកនអញ តែឆ្នាង តែកន្តំ តែបន្សំ តែកន្សុ តែសំអប តែកលង តែកន្ទេង តែកន្សំ តែកញ្ចុ តែកន្ទ្រឹប តែថ្លក តែវ្រត តែកទ្រូច តែកបកេប តែខ្នោប តែកំព្រៅ តែកំប្រូត តែកនឥន តែកំបត តែកម្ម៌ទយ តែអ្នាយ តែកន្ទេង តែខ្និរ តែតវុយ តែខ្មៅ តែសំអប តែកន្តំ តែបំនោះ តែកំប្រូត តែឆ្មោង តែធម្ម៌ តែកំបិត តែមន្ទិរ តែគង្គា តែអនឱ តែកំបិត។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

(២៤-២៥) ផ្សំអ្នក(បម្រើ)ខែខ្មើត(មាន)១៣០នាក់។

(២៥-) រៀបចំឱ្យអំរះម្នាក់ៗៈ សណ្ដែក១ដើនិង៨លិះ លូ៨លិះ រង្វ៉ូ២មាស។ ព្រះសង្វោយប្រចាំថ្ងៃ អង្ករសម្រាប់បូជាយជូ៤ថ្លាំង នំចុន សណ្ដែកហូប វទិ វទា គ្រលេង ផុរិ ផុរា ធមាយ កំបោរ(?) បរិមាណ ទឹកដោះគោ ប្រេងក្រអូប។

## វាក្យសព្ទសំខាន់ៗ

| | |
|---|---|
| **ព្រះគាសន** | ព្រះរាជសាសន៍ ព្រះរាជបញ្ជា។ |
| **ឋ្រះកម្រតេងអញ** | ព្រះគម្ដែងអញ ឋានន្តរនាមសម្គាល់មន្ត្រីថ្នាក់ខ្ពស់ ញាតិវង្ស ព្រះមហាក្សត្រ និងអាទិទេព។ |
| **វក្រ** | ក្ដីរង្កៀស សេចក្ដីសង្ស័យ សួរដេញដោល។ |
| **ខ្លោញវិថែយ** | អភិបាលខេត្ត។ |
| **តម្រួច** | តម្រួត អ្នកត្រួត។ |
| **កល្បនា** | រណ្ដាប់បូជា។ |
| **បទ្វារិកា** | ខ្នាតរង្វាល់ចំនួន៦ខារិកា។ (តាមខ្នាតរបស់តណ្ឌា ១ខារិកា មាន ប្រមាណ១៩៦គីឡូ។ |
| **ឃ្មុត** | ប៊ឺរទឹកដោះគោ។ |
| **អាឍក/អាឍកក** | ខ្នាតរង្វាល់ ដែលតាមខ្នាតតណ្ឌាមានទម្ងន់ប្រមាណជា៣គីឡូ។ |
| **ឥណ** | ទម្ងន់។ (ពាក្យនេះជាឫសរបស់ពាក្យ ទម្ងន់) |
| **ជ្យង** | ខ្នាតរង្វាល់ធញ្ញជាតិឬលោហៈដោយប្រើជញ្ជីង។ |
| **មហាណស** | ចុងភៅ។ |
| **អំរះ** | ប្រភេទអ្នកបម្រើដើរមើលរះត្រួតកិច្ចការទូទៅ។ |
| **ភនិនិ** | ល្ខោនសម្ដែងមានអ្នកពោលពីដំណើររឿង។ |
| **សិ/សី** | អ្នកបម្រើភេទប្រុស។ |
| **តៃ** | អ្នកបម្រើភេទស្រី។ |

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



ប្រាសាទដើមអង្គ (រូបថតៈ ហ៊ុន ឈុនតេង)



សិលាចារឹកមេទ្វារខាងត្បូងនិងខាងជើង (រូបថតៈ ហ៊ុន ឈុនតេង)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



*សំណៅផ្តិតសិលាចារឹកមេទ្វារខាងត្បូងនិងខាងជើងរបស់ក្រុមការងារសារមន្ទីរជាតិ*

*(រូបថត៖ ហ៊ុន ឈុនតេង)*



n. 737 S haut / K. 99 S

*សំណៅផ្តិតសិលាចារឹកមេទ្វារខាងត្បូង (រូបថត៖ EFEO)*

*អត្ថបទដោយ៖ ហ៊ុន ឈុនតេង*

## ឯកសារយោង

ហ៊ុន ឈុនតេង,

២០២១, សិលាចារឹកប្រាសាទជើងអង់ K.៩៩ ភាគ១, AMS, https://ams.com.kh/khmercivilization/detail/9827

Coedès G.,

1937. *Piédroits de Čoṅ Aṅ*, in Inscriptions du Cambodge (vol. IV). Paris, Editions de Boccard.

Jenner P.,

n.d. *Jenner manual: Part xml, № 25*. in http://sealang.net/ok/corpus.htm.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION